00274521

- ០១/១៨-០៩-២០០៧ ...
- ០២/១៩-០៩-២០០៧ ...

08-VU-01032

អង្គភាពជនរងគ្រោះ
Victims Unit E2/36
Delivery By : CHRAC
ផ្ញើដោយ :
Received By : VU
ទទួលដោយ :
Date : 09/07/08 Time : LLN
ម៉ោង :

# ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ

## ផ្នែក " ក "

## ព័ត៌មានផ្ទាល់ខ្លួនអំពីជនរងគ្រោះ

| | |
|---|---|
| ១. នាមត្រកូល និងនាមខ្លួន : រម៉ាម យុន ហៅ ខាំភី | ២.ភេទ ☑ ប្រុស ☐ ស្រី |
| ៣.ទីកន្លែងកំណើតភ.កាជូត ឃ.ញ៉ាង ស្រ.អណ្តូងមាស ខ.រតនគិរី | ៤.សញ្ជាតិ : ខ្មែរ |
| ៥.អាយុ/ថ្ងៃខែឆ្នាំកំណើត : ៧៥ ឆ្នាំ | ៦.មុខរបរ : ធ្វើចំការ |
| ៧.ស្ថានភាពគ្រួសារ : ☐ នៅលីវ ☑ រៀបការ ☐ លែងលះ ☐ ពោះម៉ាយ ☐ ផ្សេងៗ | |
| ៨.ឈ្មោះឪពុក ឬអាណាព្យាបាល : ប៉ូយ ក្វាត | ឈ្មោះម្តាយ : រម៉ាម ប៊ិត |
| ៩.តើមានអ្នកនៅក្នុងបន្ទុកចំនួនប៉ុន្មាននាក់ ? សូមសរសេរជាលេខ : ៤ នាក់ | |
| ១០.តើអ្នកធ្លាប់ពិការភាពពីមុនឬទេ ? ☐ បាទ ឬចាស ☑ ទេ<br>ប្រសិនបើឆ្លើយថាបាទ ឬចាសសូមរៀបរាប់អោយលំអិត : | |
| ១១.តើភស្តុតាងនៃអត្តសញ្ញាណខាងក្រោមណាមួយដែលអ្នកមាន ? សូមបញ្ជាក់ជាលេខ | |

| ប្រភេទនៃភស្តុតាងនៃអត្តសញ្ញាណ | លេខ និង យោងផ្សេងៗ |
|---|---|
| ☐ លិខិតឆ្លងដែន | |
| ☐ បណ្ណ័បើកបររថយន្ត | |
| ☐ អត្តសញ្ញាណប័ណ្ណ( ដូចជាកាតសំគាល់និស្សិត.បុគ្គលិក) | |
| ☐ លិខិតបញ្ជាក់ពីអញ្ញោធរដែនដី | |
| ☐ លិខិតចុះឈ្មោះនៅក្នុងជំរុំ | |
| ☐ កាតសំគាល់ចេញដោយអង្គការមនុស្សធម៌ ( ដូចជា UNHCR WFP ) | |
| ☐ ឯកសារពន្ធ | |
| ☐ ប័ណ្ណបោះឆ្នោត | |
| ☐ | |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 01 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.



Declassified to Public
06 September 2012

E2/36

| | |
|---|---|
| ផ្សេងៗ | |
| ☑ គ្មាន | |

| |
|---|
| សំរាប់អង្គភាពជនរងគ្រោះតែប៉ុណ្ណោះ |
| ពាក្យស្នើសុំ : |
| ☐ សាក្សី ☐ ពាក្យបណ្តឹង ☐ ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី |
| សំរាប់ : |
| ☐ សហព្រះរាជអជ្ញា ☐ សហចៅក្រមស៊ើបអង្កេត |

| | |
|---|---|
| ១២.សូមបំពេញគ្រប់ចំនុចដែលត្រូវការសំរាប់លោកអ្នក | |
| ☑ អាស័យដ្ឋានបច្ចុប្បន្ន ☐ ប្រសិនបើអ្នកមិនមានអាស័យដ្ឋានពិតប្រាកដ | |
| លេខ/ប្លុក : | ផ្លូវ : |
| ក្រុម/ភូមិ : កាជូត | ឃុំ/សង្កាត់ : ញ៉ាង |
| ស្រុក/ខណ្ឌ : អណ្តូងមាស | ខេត្ត/ក្រុង : រតនគិរី |
| ប្រទេស : កម្ពុជា | |
| ១៣.អាស័យដ្ឋានសំរាប់ទំនាក់ទំនង *សូមគូសទៅតាមភាពសមស្រប* . | |
| ☐ ខ្ញុំចង់អោយទៅទាក់ទងទៅតាមអាស័យដ្ឋានដូចមាននៅក្នុងចំនុចលេខ ១២ : | |
| ☐ ខ្ញុំចង់អោយទាក់ទងទៅតាមរយះបុគ្គលដែលជាតំណាងរបស់ខ្ញុំដូចខាងក្រោម :<br>☐ មេធាវី ☐ សមាគមជនរងគ្រោះ | |

00274523

E2/36

| | |
|---|---|
| ☑ ខ្ញុំចង់អោយទាក់ទងទៅតាមអាស័យដ្ឋានដូចខាងក្រោម : | |
| លេខ/ប្លុក : ៣ | ផ្លូវ : ១៩៨ |
| ក្រុម/ភូមិ : | ឃុំ/សង្កាត់ : បឹងរាំង |
| ស្រុក/ខណ្ឌ : ដូនពេញ | ខេត្ត/ក្រុង : ភ្នំពេញ |
| ប្រទេស : កម្ពុជា | |
| ☐ ខ្ញុំចង់អោយទាក់ទងទៅតាមទូរស័ព្ទនេះ : គ្មាន | |

តើអ្នកធ្លាប់បានប្តឹង ឬ ដាក់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ឬកន្លែងណាមួយផ្សេងទៀត ?

☐ បាទ/ចាស ☑ ទេ

ប្រសិនបើឆ្លើយថា បាទ/ចាស សូមមេត្តាបញ្ជាក់អំពីពាក្យស្នើសុំ នៅពេលណា និង ទីកន្លែងណា

ពាក្យស្នើសុំ

ទីកន្លែង: ថ្ងៃ ខែ ឆ្នាំ

**<u>ផ្នែក " ខ "</u>**

**ព័ត៌មានទាក់ទងនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់**

**១. សូមផ្តល់នៅព័ត៌មានពិស្តារអំពីឧក្រិដ្ឋកម្ម**

**ទីកន្លែង** : : - គុកទួលស្លែង ទីក្រុង ភ្នំពេញ

**កាលបរិច្ឆេទ** : - ខែ កញ្ញា ឆ្នាំ ១៩៧៥

**<u>ការពិពណ៌នាអំពីឧក្រិដ្ឋកម្ម</u> :** ( តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើង ហើយកើតឡើងដោយរបៀបណា ? )

ខ្ញុំបាទឈ្មោះ រម៉ាម យុន ហៅ ខាំ ភី ភេទ ប្រុស អាយុ ៧៥ ឆ្នាំ ជាជាតិភាគតិចកាចក់ រស់នៅ ភូមិ កាជូត ឃុំ ញ៉ាង ស្រុក អណ្តូងមាស ខេត្ត រតនគិរី ។ កាលពីសម័យ លន់ ណុល ខ្ញុំមានមុខរបរជាកសិករធ្វើស្រែចំការ រស់នៅជាសមូហភាពតាមបែបប្រពៃណីរបស់បងប្អូនជនជាតិភាគតិចកាចក់ គឺធ្វើតាមបែបធម្មជាតិសុទ្ធសាធមានតិច ហូបតិចមានច្រើនហូបច្រើន តាមលទ្ធភាពដែលខ្លួនអាចរកបាន ។ចំពោះការងារកសិកម្ម បងប្អូនភាគតិចយើងចូលចិត្ត ធ្វើការរួម មិនចូលចិត្តធ្វើការតែឯង១នោះទេដូចជាការបរបាញ់សត្វពេលបាន តែងតែនាំយកមកចែកគ្នា បើមានជំងឺឈឺ ថ្កាត់អ្វីផ្សេង១ បងប្អូនជនជាតិគតិចយើង ភាគច្រើនត្រូវតែសែនអារក្ស ព្រោះការឈឺនេះអាចមកពីអារុក្ខអារក្សអ្នកតា ជាអ្នកធ្វើអោយឈឺទើបឈឺ ។ ជំនឿនេះមានតាំងពីដូនតាដែលបងប្អូនជនជាតិភាគតិចយើងមិនអាចបំភ្លេចបាន ។លុះ របបលន់ ណុលដួលរលំ ចូលដល់សម័យ ប៉ុល ពត ប្រពៃណីទាំងនេះត្រូវបាត់រូបរាងទាំងអស់ ប្រជាជនត្រូវប្តូរ ឥរិយាបថថ្មី ដោយមានការជន្លៀសប្រជាជនពីតំបន់មួយ ទៅតំបន់មួយក្នុងចំនោមបងប្អូនជនជាតិភាគតិច ។ របស់របរ សត្វពាហនៈ ទៀតសោតត្រូវប្រមូលទុករួម ដូចជា គោ ក្របី ជាដើម ។ ចំនែករូបខ្ញុំត្រូវប្រធានតំបន់ឈ្មោះថា មិត្ត យ៉ា ជាប្រធាន ប្រចាំភូមិភាគឥសាន្ត បានតែងតាំងរូបខ្ញុំ អោយធ្វើជាអនុប្រធានតំបន់ ១០១ កាន់កាប់មើលការខុស ត្រូវលើការធ្វើស្រែចំការរបស់ប្រជាជននៅស្រុកវើសៃ ខេត្ត រតនគិរី ។

**-ពាក់កណ្តាលឆ្នាំ ១៩៧៧** : មានការបើកសន្និបាតមួយនៅខេត្ត ស្ទឹងត្រែង ។ តាមការរៀបចំរបស់ ប៉ុល ពត ដោយមានការចូលរួមពីប្រធាន អនុប្រធានតាមតំបន់ភូមិភាគនីមួយ១ ពេលនោះក៏មានវត្តមានរូបខ្ញុំដែរ ។ ពេលកំពុង សន្និបាត

00274525

E2/36

ស្រាប់តែមានមនុស្សម្នាក់មិនដឹងជាអនុ ឬប្រធាននៅតំបន់ណាមួយទេមកខ្សឹបប្រាប់ខ្ញុំថា ម្នាក់នោះ ជា តាម៉ុក ម្នាក់នោះ ជា ប៉ុល ពត ម្នាក់នេះជា នួន ជា ម្នាក់នោះ អៀង សារី ម្នាក់នេះខៀវ សំផន ម្នាក់នោះ ឌុច តែខ្ញុំមើលមិន ច្បាស់សោះព្រោះវាឆ្ងាយពេក ។ក្នុងសន្និបាតនោះគឺប៉ុល ពត និយាយតែម្នាក់ឯង ម្យ៉ាងសម្តីរ របស់ គាត់ ខ្ញុំចាំមិនបានទេ ។

- **ខែ កញ្ញា ឆ្នាំ ១៩៧៨** : រូបខ្ញុំត្រូវបានប្រធានប្រចាំភូមិភាគឥសាន្តឈ្មោះ យ៉ា បានចាត់អោយទៅកាន់ ភ្នំពេញ រួមដំណើរជាមួយមិត្ត ក្លាន ហ្វិត រស់នៅ ភូមិ អ៊ុន ឃុំ តាឡាវ ស្រុក អណ្តូងមាស ខេត្ត រតនគិរី ដែលមានឋានៈជាអនុលេខាប្រចាំស្រុកអណ្តូងមាស បានធ្វើដំណើរតាមការឡាន ចេញពីស្រុក វើនសៃ ខេត្ត រតនគិរី ឆ្ពោះទៅ កាន់ខេត្ត ស្ទឹងត្រែង ព្រោះនូវមានមិត្ត ៦នាក់ នាក់ទៀតកំពុងរងចាំខ្ញុំនៅទីនោះ មិត្តទី ១ ឈ្មោះ មិត្ត ភុង ជនជាតិ ព្រៅ មានស្រុកកំនើតនៅ ឃុំ កាចាញ ស្រុក បានលុង ខេត្ត រតនគិរី ឯមិត្តទី ២ ឈ្មោះ មិត្ត ផា ជនជាតិឡាវ ជាគណៈ ស្រុក សែ្រគរ ខេត្ត ស្ទឹងត្រែង ទី ៣ ឈ្មោះ មិត្ត យ៉ង ជនជាតិ លុន ជាគណៈស្រុកសៀមប៉ាង ទី ៤ ឈ្មោះ មិត្ត ប៉យ ជាគណៈស្រុក ២១ ស្រុក វើនសៃ ទី៥ មិត្ត វ៉ន ជាអនុប្រធានតំបន់ស្ទឹងត្រែងខេត្ត ស្ទឹងត្រែង នឹងមិត្ត ២ នាក់ទៀតឈ្មោះ មិត្ត យ៉ង់ មិត្ត ឆុម(ភ្លេចងារក្នុងសម័យខ្មែរក្រហម) ព្រមទាំងមានការជូនដំណើរដោយ តា ខេង ជាប្រធាន កងពលភូមិភាគឥសាន្ត និងងារមួយទៀតជា ប្រធានភូមិភាគឥសាន្ត និងអង្គរក្សម្នាក់ទៀតឈ្មោះ មាន ប្រដាប់ដោយ កាំភ្លើងអាកាបត់មួយដើម និងអ្នកបើកកាឡានចំនួន ២នាក់(មិនស្គាល់ឈ្មោះ)រួចក៏បើកឆ្ពោះទៅកាន់ទីក្រុង ភ្នំពេញ ២ យប់ ២ ថ្ងៃទើបទៅដល់ទីក្រុងភ្នំពេញ ។ ពេលទៅដល់ភ្លាមតា ខេង និង តាមាន ក៏បានជូនដំណើរពួកខ្ញុំទៅផ្ទះមួយឈ្មោះ ថា ផ្ទះចាងហ្វាងខេត្ត ស្ថិតនៅទីក្រុងភ្នំពេញស្នាក់នៅទីនោះទាំងអស់គ្នា ១យប់។ ។លុះព្រឹកឡើងម៉ោងប្រហែលល ៦ ព្រឹក តា ខេង និង តាមាន ក៏ជិះកាឡានធ្វើ ដំណើរត្រលប់មកកាន់ខេត្ត ស្ទឹងត្រែង វិញ ។ ចំណែកឯមិត្ត ប៉យ មិត្ត យ៉ង មិត្ត ឆុម ត្រូវគេបញ្ជូន ទៅកាន់កន្លែងផ្សេង ដោយមានឡានគ្របស្តង់មកយក ។កាលហ្នឹងមានតែកុង ២ នាក់(មិនស្គាល់ឈ្មោះ) ជាអ្នកនាំពួក គាត់ទៅ ដោយគេថា អង្គការអោយទៅប្រជុំ ។កាលហ្នឹងលឺ ថាយកទៅទួលស្លែង ក្រោយមកក៏បាត់ដំណឹងរហូត។ ឯរូបខ្ញុំ មិត្ត ផា មិត្ត ក្លាន ហ្វិត មិត្ត ភុង ឃើញស្ថានភាពដូចនេះ ធ្វើអោយខ្ញុំភ័យរកទៅចងកសំលាប់ខ្លួន តែត្រូវមិត្ត ក្លាន ហ្វិតជាអ្នកឃាត់ ។ លុះទ័ពវៀតណាមវាយចូលទីក្រុងភ្នំពេញ ខ្ញុំរួមទាំងមិត្ត ៣ នាក់ក៏ភៀសខ្លួនចេញពីទីក្រុងភ្នំពេញ ចេះតែធ្វើដំណើរផ្សេងប្រេងបន្តិច ម្តងៗរហូតមកដល់ខេត្ត រតនគិរីដែលជា ស្រុកកំនើត ។

២.តើអ្នកណាខ្លះដែលអ្នកជឿថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ហើយមូលហេតុអ្វីបានជាអ្នកជឿជាក់បែបនេះ ?

សូមឆ្លើយតាមសំនួរនេះទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន :

**១-ឈ្មោះ នួន ជា** អតីតប្រធានសភាសម័យកម្ពុជាប្រជាធិបតេយ្យ

**២-ឈ្មោះ អៀង សារី** អតីតឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ

**៣-ឈ្មោះ ខៀវ សំផន** អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ

00274526

E2/36

៤-ឈ្មោះ **ហ្គាំង ហ្កេចអ៊ាវ** ហៅ ឌុច ជាប្រធានប្រធានគុកទួលស្លែង នៃរបបកម្ពុជាប្រជាធិបតេយ្យ

៥-មិត្ត **យ៉ា** ជាប្រធានភូមិភាគឥសាន្ត

- បច្ចុប្បន្នមិនដឹងរស់នៅទីណា ?

៦-មិត្ត **ខេង** ជាប្រធានកងពលភូមិភាគឥសាន្ត និងជាប្រធានតំបន់ភូមិភាគឥសាន្ត

៧- មិត្ត **មាន** អង្គរក្សមិត្ត ខេង

- បច្ចុប្បន្នមិនដឹងរស់នៅទីណា ?

- ព្រោះអ្នកទាំងនេះសុទ្ធតែជាអ្នកដែលមានឥទ្ធិពលខ្លាំង ក្នុងរបបដែលខ្លួនកាន់កាប់អំណាច ម៉្យាងសុទ្ធតែជាអ្នកដែលត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់បងប្អូនជនជាតិភាគតិចរបស់ខ្ញុំ ។

៣.តើអ្នកជាជនរងគ្រោះក្នុងឧក្រិដ្ឋកម្មទាំងនោះដែរឬទេ ? ☑ បាទ/ចាស ទេ ☐

៤.តើអ្នកជាសាក្សីក្នុងឧក្រិដ្ឋកម្មទាំងនោះដែរឬទេ ? ☐ បាទ/ចាស ទេ ☑

៥..តើអ្នកបានដឹងជនរងគ្រោះ ឬសាក្សី នៅក្នុងឧក្រិដ្ឋកម្មទាំងនោះដែរឬទេ ? ☑ បាទ/ចាស ទេ ☐

( ប្រសិនបើឆ្លើយថា បាទ/ចាស និងប្រសិនបើអ្នកមានលទ្ធភាព សូមផ្តល់ឈ្មោះនិងអាស័យដ្ឋានរបស់ពួកគេ លើកលែងតែ អ្នកដឹងថាពួកគេចង់នៅអនាមិក ឬវាអាចធ្វើអោយមានហានិភ័យចំពោះអ្នក ឬអ្នកណាផ្សេងៗទៀត )

**សាក្សី:**

១-មិត្ត **យ៉ា** ជាប្រធានភូមិភាគឥសាន្ត

- បច្ចុប្បន្នមិនដឹងរស់នៅទីណា ?

-មិត្ត **ខេង** ជាប្រធានកងពលភូមិភាគឥសាន្ត និងជាប្រធានតំបន់ភូមិភាគឥសាន្ត

២- មិត្ត **មាន** អង្គរក្សមិត្ត **ខេង**

- បច្ចុប្បន្នមិនដឹងរស់នៅទីណា ?

៣- ឈ្មោះ **ក្លាន ហ៊ិត ជនជាតិ កាចក់**

- បច្ចុប្បន្ន : រស់នៅភូមិ អ៊ិន ឃុំ ញ៉ាង ស្រុក អណ្តូងមាស ខេត្ត រតនគីរី



00274527

E2/36

៤-ឈ្មោះ **ភុង ជនជាតិភាគតិច ព្រៅ**

- បច្ចុប្បន្ន : ស្លាប់

៥- ឈ្មោះ **ជា ជនជាតិឡាវ**

- បច្ចុប្បន្ន :រស់នៅ ស្រុក សៀមប៉ាង ខេត្ត ស្ទឹងត្រែង ( មិនដឹងរស់ ឬស្លាប់ )

**ជនរងគ្រោះ :**

១-មិត្ត **យ៉ង** ជនជាតិ លុន ជាគណៈស្រុកសៀមប៉ាង សម័យខ្មែរក្រហម

២- ឈ្មោះ មិត្ត **ប៉យ** ជាគណៈស្រុក ២១ ស្រុក វើនសៃ សម័យខ្មែរក្រហម

៣- មិត្ត **វិន** ជា អនុប្រធានតំបន់ស្ទឹងត្រែងខេត្ត ស្ទឹងត្រែង សម័យខ្មែរក្រហម

៤-មិត្ត **នុម**( ភ្លេចងារក្នុងសម័យខ្មែរក្រហម)

៦.តើអ្នកមានទំនាក់ទំនងអ្វីជាមួយសាក្សីទាំងនោះ ( ជាក្រុមគ្រួសារ . អ្នកជិតខាង . **មិត្តភ័ក្ត** .។ល។ )? ☑ បាទ/ចាស ☐ ទេ

( ប្រសិនបើឆ្លើយថាបាទ/ចាស. សូមបញ្ជាក់ ) :

១- ឈ្មោះ **ក្វាន ហ៊ិត ជនជាតិ កាចក់**

- បច្ចុប្បន្ន : រស់នៅភូមិ អ៊ិន ឃុំ តាឡាវ ស្រុក អណ្តូងមាស ខេត្ត រតនគិរី

២- ឈ្មោះ **ភុង ជនជាតិ ព្រៅ**

- បច្ចុប្បន្ន : ស្លាប់

៣- ឈ្មោះ **ជា ជនជាតិឡាវ**

- បច្ចុប្បន្ន :រស់នៅ ស្រុក សៀមប៉ាង ខេត្ត ស្ទឹងត្រែង

E2/36

| |
|---|
| ដើម្បីអនុញ្ញាតិអោយដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមបាន . ព្យសនកម្មត្រូវតែជា ក) រូបកាយ សម្ភារៈ ឬ ផ្លូវចិត្ត ខ) ប៉ះពាល់ដោយ ផ្ទាល់ពីបទល្មើសនោះជាលក្ខណៈបុគ្គល និងមានឥទ្ធិពលរហូតមកដល់បច្ចុប្បន្ន ។ |

**ផ្នែក " គ "**

**ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

| |
|---|
| *អ្នកត្រូវបំពេញក្នុងផ្នែកនេះ ប្រសិនបើអ្នកមានបំណងចង់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការស៊ើបសួរ* |
| ១.សូមបញ្ជាក់អំពីដំណាក់កាលនីតិវិធីដែលអ្នកមានបំណងចង់ចូលរួម : **ដំណាក់កាលស៊ើបអង្កេត**<br>សំណុំរឿងលេខ : ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស<br>០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស |
| ២.សូមបញ្ជាក់អំពីព្យសនកម្ម ការបាត់បង់ ឬផលវិបាកដែលបានទទួលនិងសូមធ្វើការអត្ថាធិប្បាយដោយសង្ខេប<br>( ដូចជាព្យសនកម្មទៅលើរូបកាយ ផ្លូវចិត្ត និងភាពតានតឹងនៅក្នុងចិត្ត បាត់បង់ ឬ ខូចខាតនូវទ្រព្យសម្បត្តិ<br>**ព្យសនកម្មលើផ្លូវកាយ :**<br>-ត្រូវធ្វើដំណើរដោយថ្មើរជើងពីភ្នំពេញមកាន់ខេត្ត រតនគីរី<br>**ព្យសនកម្មផ្លូវចិត្ត :**<br>- នឹកស្តាយមិត្តភ័ក្តដែលបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម<br>- បង្ខាំងខ្លួនដោយគ្មានមូលហេតុ<br>- ខឹងចំពោះមេដឹកនាំធំៗដែលបង្កើតរបបនេះឡើង<br>**ព្យសនកម្មសម្ភារៈ**<br>- ផ្ទះសម្បែង |
| ៣.តើអ្នកត្រូវបានវេជ្ជបណ្ឌិតពិនិត្យក្រោយពីព្រឹត្តការណ៍នោះកើតឡើងឬទេ ? ☐ បាទ/ចាស ☑ ទេ |
| ៤.តើអ្នកបានព្យាបាលដោយប្រើប្រាស់ថ្នាំ ឬ ដោយវិធីព្យាបាលផ្លូវចិត្តដែរឬទេ ? ☐ បាទ/ចាស ☑ ទេ |
| ៥..ប្រសិនបើ បាទ/ចាស តើអ្នកមានកំណ... ប្រើប្រាស់ថ្នាំ ឬដោយវិធីព្យាបាលផ្លូវចិត្តទាំងនោះដែរឬទេ? ☐ បាទ/ចាស ☑ ទេ |

ប្រសិបើឆ្លើយថា បាទ/ចាស  សូមគូសទៅតាមភាពសមស្របខាងក្រោម និងផ្តល់ឯកសារចំលងមួយច្បាប់ប្រសិនបើអាច

☐ របាយការណ៍វេជ្ជៈបណ្ឌិត  មន្ទីរពេទ្យ ឬមណ្ឌលសុខភាព ☐ កាំរស្មី X ☐ វេជ្ជបញ្ជា /វិក័យប័ត្រថ្នាំ

☐ ផ្សេងៗសូមបញ្ជាក់ ☐ មិនមានអ្វីទាំងអស់ដូចខាងលើ

៦.តើស្ថានភាពនៃព្យសនកម្មនោះមានរហូតមកដល់សព្វថ្ងៃដែររឺទេ ? ☑ បាទ/ចាស ☐ ទេ

**ប្រសិនបើឆ្លើយ បាទ/ចាស សូមបញ្ជាក់អោយបានពិស្តារ :**

ពេលនឹកឃើញពីរបបខ្មែរក្រហម  កាលណាធ្វើអោយខ្ញុំមានអារម្មណ៍ខឹងទៅលើមេដឹកនាំធំៗទាំងនោះ  ជាពិសេសនឹកស្តាយមិត្តភ័ក្តដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហម ម៉្យាងនឹកឃើញពីជីវិតដ៏កំសត់ជាប់ជានិច្ចពេលធ្វើដំណើរពីភ្នំពេញមកកាន់ខេត្ត រតនគីរី ។

៧.តើអ្នកមានបំណងចង់ទាមទារអោយមានសំណងជាលក្ខណៈសមូហភាព ឬជាផ្លូវចិត្តណាមួយដែររឺទេ ? ☑ បាទ/ចាស ☐ ទេ

ប្រសិនបើឆ្លើយ បាទ / ចាស សូមបញ្ជាក់អោយបានពិស្តារ  :

**ចំពោះសំណងរួម:**ខ្ញុំចង់តាមទារអោយខាងសាលាក្តីខ្មែរក្រហមជួយសាងសង់មន្ទីរពេទ្យ  វត្ត អារាម សាលារៀន  សាងសង់មជ្ឈមណ្ឌលកុមារកំព្រា  ចាស់ជរា  សំរាប់ខេត្ត រតនគីរី  ។

**សំណងបុគ្គល :**ត្រាក់ទ័រព្សរដី ១ គ្រឿង

E2/36

**ផ្នែក "ឃ"**

**ហត្ថលេខា**

១.ហត្ថលេខាជនរងគ្រោះ

*សូមមេត្តាចុះហត្ថលេខា ឬផ្តិតម្រាមមេដៃ និងចុះកាលបរិច្ឆេទនៅលើបែបបទនេះ ទោះបីជានណារម្នាក់ធ្វើក្នុងនាមរបស់អ្នក ឬមាននរណាម្នាក់ជួយអ្នកក្នុងការបំពេញបែបបទនេះ*

ខ្ញុំសូមបញ្ជាក់ថា :

-ព័ត៌មានទាំងអស់ដែលបានផ្តល់ក្នុងបែបបទនេះពិតជាត្រឹមត្រូវពិតប្រាកដមែនប្រសិនបើមានចំនុចណាមិនពិតខ្ញុំសូមទទួលទោសតាមច្បាប់ជាធរមាន

-ខ្ញុំមានបំណងចង់ចូលរួមក្នុងនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ជា : ☐ សាក្សី ☐ ជាអ្នកប្តឹង ☑ ដើមបណ្តឹងរដ្ឋប្បវេណី

*ប្រសិនបើចង់តាំងខ្លួនជា "ដើមបណ្តឹងរដ្ឋប្បវេណី" សូមបញ្ជាក់អោយច្បាស់ថាបានបំពេញនៅក្នុងផ្នែក "គ"*

ទីកន្លែងធ្វើ : ខេត្ត តាកែវ — ថ្ងៃ 20 ខែ មិថុនា ឆ្នាំ 2008

ហត្ថលេខា ឬស្នាមម្រាមដៃជនរងគ្រោះ និង ឈ្មោះ

ឈ្មោះសាក្សី : [illegible]

ហត្ថលេខាសាក្សីក្នុងការបំពេញ — ហត្ថលេខា.......[illegible]

២.ហត្ថលេខាបុគ្គលដែលជាអ្នកតំណាងអោយជនរងគ្រោះដោយមានការយល់ព្រមពីជនរងគ្រោះ

ដោយមានការយល់ព្រមពីជនរងគ្រោះ :

ខ្ញុំឈ្មោះ

ឈ្មោះជនរងគ្រោះ

យល់ព្រមអោយឈ្មោះ ធ្វើជាតំណាង

*សរសេរឈ្មោះបុគ្គលដែលជាអ្នកតំណាងអោយជនរងគ្រោះ ក្នុងនាមនៃ*

00274531

E2/36

អោយបំពេញបែបបទនិងដាក់ពាក្យសុំនេះ

ទីកន្លែងធ្វើ : ថ្ងៃ ខែ ឆ្នាំ

ហត្ថលេខា ឬស្នាមម្រាមដៃរបស់បុគ្គលដែលជាតំណាងអោយជនរងគ្រោះ និងឈ្មោះ

ឈ្មោះសាក្សី :

ហត្ថលេខាសាក្សីក្នុងការបំពេញ : ហត្ថលេខា....................................................

នៅមុនពេលដាក់បែបបទពាក្យស្នើសុំនេះ សូមពិនិត្យមើលឡើងវិញ និងគូសនៅខាងក្រោមនេះទៅតាមការសមស្រប :

☑ ខ្ញុំបានភ្ជាប់ជាមួយក្នុពាក្យសុំនេះនូវឯកសារដូចខាងក្រោម

- រូបថត ១ សន្លឹក

☑ ខ្ញុំបានចុះហត្ថលេខាឬផ្តិតម្រាមនៅគ្រប់ទំព័រនៃបែបបទនិងឯកសារដែលភ្ជាប់មកជាមួយ

សូមបញ្ជាក់អំពីចំនួនសរុបនៃទំព័ររបស់ទំរង់បែបបទនេះរួមទាំងទំព័របន្ថែម និងឯកសារភ្ជាប់ផ្សេងទៀត : ១២ ទំព័រ

| **ជនរងគ្រោះ** | បុគ្គតំណាងអោយជនរងគ្រោះ |
|---|---|
| ☑ ខ្ញុំបានផ្តល់សេចក្តីចំលងនៃឯកសារជាភស្តុតាងនៃអត្តសញ្ញាណឆ្លើយតបទៅនឹងតំរូវការនៅក្នុងសំនួរទី១១នៃផ្នែក "ក" ។<br>☑ ខ្ញុំបានផ្តល់ព័ត៌មានឆ្លើយតបទៅហ្នឹងតំរូវការនៅក្នុងសំណួរទី ១៣ នៃផ្នែក "ក" ។<br>☑ ខ្ញុំបានចុះហត្ថលេខា ឬផ្តិតម្រាមនៅក្នុងប្រអប់ទី ១ នៅ ក្នុងផ្នែក "ឃ" | ☐ ខ្ញុំបានចុះហត្ថលេខាឬផ្តិតម្រាមដៃនៅក្នុងប្រអប់ទីពីរនៅក្នុងផ្នែក "ឃ"<br> |